## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :...............១៣១...........ក.ប/ស.ជ.ព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េពិសេសក្រោមប្រព័ន្ធអនុញ្ញាតមុខរបរលើកទី២ សម្រាប់ឆ្នាំ២០១៤ (2nd Special EPS-TOPIK)

យោងលិខិតលេខEPST-៤២៦០ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ របស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD-KOREA) គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស(MTOSB)មានកិត្តិយសសូមជូនដំណឹងដល់សាធារណជនអំពីការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េពិសេស(Special EPS-TOPIK) តាមប្រព័ន្ធកុំព្យូទ័រសម្រាប់វិស័យឧស្សាហកម្ម វិស័យកសិកម្ម វិស័យសំណង់ វិស័យនេសាទ និងវិស័យសេវាកម្មដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

### ១- ការចែក និងទទួលពាក្យប្រឡង

- ថ្ងៃច័ន្ទ ទី១៩ ដល់ថ្ងៃពុធ ទី២១ ខែឧសភា ឆ្នាំ២០១៤
- នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)
- ចាប់ពីម៉ោង០៨:៣០ ដល់១៦:៣០ (សម្រាកអាហារថ្ងៃត្រង់១២:០០-១៣:០០)

### ២-លក្ខខណ្ឌដើម្បីដាក់ពាក្យប្រឡង

មានតែបេក្ខជនដែលមានឈ្មោះក្នុង *បញ្ជីឈ្មោះបេក្ខជនអាចដាក់ពាក្យប្រឡង* ដែលមានបិទផ្សាយនៅលើក្តារខៀនព័ត៌មាននៃគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ហើយបំពេញតាមលក្ខខណ្ឌដូចខាងក្រោមប៉ុណ្ណោះដែលអាចដាក់ពាក្យប្រឡងបាន៖

១. បេក្ខជនដែលធ្លាប់បន្តកិច្ចសន្យាការងារ និងចាកចេញពីសាធារណរដ្ឋកូរ៉េមុនថ្ងៃផុតកំណត់កិច្ចសន្យាការងារដោយស្របច្បាប់(ត្រលប់មកកម្ពុជាក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១០)
២. បេក្ខជនដែលមានអាយុចាប់ពី១៨ ដល់៣៩ឆ្នាំ (កើតនៅចន្លោះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៤ ដល់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៦)
៣. បេក្ខជនដែលមិនធ្លាប់ធ្វើការខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ និងមិនដែលត្រូវបានបណ្តេញចេញពីសាធារណរដ្ឋកូរ៉េ
៤. បេក្ខជនដែលមិនធ្លាប់ជាប់ពន្ធនាគារ ឬទោសឧក្រិដ្ឋធ្ងន់ធ្ងរ
៥. បេក្ខជនដែលមិនត្រូវបានហាមឃាត់ឲ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជា

### ៣- កាលវិភាគប្រឡង

ការប្រឡងនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ដោយក្នុងមួយថ្ងៃមានការប្រឡងពីរវេនគឺ៖

- ការប្រឡងវេនទី១ (ចំនួនបេក្ខជន ៣៥នាក់)
  - ការពន្យល់ណែនាំអំពីរបៀបប្រឡង ៖ ម៉ោង ០៨:៣០ - ០៩:៣០
  - ម៉ោងប្រឡង ៖ ម៉ោង ០៩:៣០ - ១០:៤០

  ※ បេក្ខជនត្រូវចូលក្នុងបន្ទប់ប្រឡងឲ្យបានមុនម៉ោង០៨:៣០ដើម្បីទទួលការពន្យល់ណែនាំអំពីរបៀបប្រឡង។
- ការប្រឡងវេនទី២ (ចំនួនបេក្ខជន ៣៥នាក់)

- ការពន្យល់ណែនាំអំពីរបៀបប្រឡង ៖ ម៉ោង ១០:៥០ – ១១:៥០
- ម៉ោងប្រឡង ៖ ម៉ោង ១១:៥០ – ១៣:០០

※ បេក្ខជនត្រូវចូលក្នុងបន្ទប់ប្រឡងឲ្យបានមុនម៉ោង១០:៥០ដើម្បីទទួលការពន្យល់ណែនាំពីរបៀបប្រឡង។

### ៤-ចំនួនបេក្ខជនប្រឡងជាប់

- ចំនួនបេក្ខជនដែលប្រឡងជាប់នឹងផ្សព្វផ្សាយនៅពេលក្រោយដោយជ្រើសរើសពីបេក្ខជនដែលមានពិន្ទុចាប់ពី៨០លើពិន្ទុសរុប២០០ទៅតាមលំដាប់ពិន្ទុពីខ្ពស់មកទាបដោយមិនគិតពីវិស័យការងារ។

### ៥-កាលបរិច្ឆេទបិទឈ្មោះប្រឡង និងមណ្ឌលប្រឡង៖

- ការបិទឈ្មោះប្រឡង ៖ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា(NPIC)
- មណ្ឌលប្រឡង ៖ ស្ថិតនៅជាន់ទី១នៃអាគារលេខ ៨ នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC)
- ព័ត៌មានអំពីការប្រឡងនឹងជម្រាបជូនតាមរយៈគេហទំព័រនៃ EPS-TOPIK(http://www.epstopik.hrdkorea.or.kr) និងបិទផ្សាយលើក្តារព័ត៌មាននៃគណៈកម្មាធិការបណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេស (MTOSB)

### ៦- របៀបនៃការចុះឈ្មោះ

- បេក្ខជនត្រូវមកចុះឈ្មោះដោយផ្ទាល់
- ឯកសារចាំបាច់ ៖
  - ពាក្យសុំសិទ្ធិប្រឡង (តម្លៃ២៤ដុល្លារអាមេរិក)
  - លិខិតឆ្លងដែនច្បាប់ដើម(លិខិតឆ្លងដែនធ្លាប់ប្រើនៅសាធារណរដ្ឋកូរ៉េ)។ បេក្ខជនត្រូវថតចម្លងលិខិតឆ្លងដែន(ពណ៌ធម្មជាតិ)ចំនួន០១ច្បាប់ដើម្បីភ្ជាប់ជាមួយពាក្យសុំសិទ្ធិប្រឡង
  - រូបថត ៣.៥ x ៤.៥ ចំនួន ០២សន្លឹក (ថតក្នុងរយៈពេល ០៣ខែចុងក្រោយ)

### ៧- វិញ្ញាសាប្រឡង

- វិញ្ញាសាអានមានចំនួន២៥សំណួរ (៤០នាទី) និងវិញ្ញាសាស្តាប់មានចំនួន២៥សំណួរ (៣០នាទី)។ វិញ្ញាសាទាំងពីរនឹងត្រូវអនុវត្តជាបន្តបន្ទាប់ដោយគ្មានការឈប់សម្រាក។
- សម្ភារ និងឯកសារដែលត្រូវយកមកជាមួយក្នុងថ្ងៃប្រឡង
  - បង្កាន់ដៃអនុញ្ញាតប្រឡង
  - លិខិតឆ្លងដែនច្បាប់ដើមដែលមានព័ត៌មានដូចគ្នាទៅនឹងព័ត៌មានដែលបានដាក់ក្នុងពាក្យសុំសិទ្ធិប្រឡង។

### ៨- ការប្រកាសលទ្ធផលប្រឡង

- លទ្ធផលនឹងត្រូវបិទផ្សាយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ នៅលើក្តារព័ត៌មាននៅគណៈកម្មាធិការបណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេស(MTOSB) និងគេហទំព័រ:http://www.eps.go.kr ឬhttp://www.epstopik.hrdkorea.or.kr ។
- សុពលភាពនៃលទ្ធផលប្រឡងមានរយៈពេល២ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសលទ្ធផល។

### ៩- ព័ត៌មានផ្សេងៗ

- បេក្ខជនដែលប្រឡងជាប់តេស្តភាសាកូរ៉េពិសេសនេះនឹងទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជាការចុះឈ្មោះស្វែងរកការងារដោយប្រើរយៈពេលខ្លី និងមិនចាំបាច់ទទួលការបណ្តុះបណ្តាលមុនចេញដំណើរ។
- នៅថ្ងៃប្រឡងមិនអនុញ្ញាតឲ្យយកចូលក្នុងបន្ទប់ប្រឡងនូវទូរស័ព្ទដៃ ម៉ាញេចាក់កាសែតPDA, MP3 Player, វចនានុក្រមអេឡិចត្រូនិច ព្រមទាំងឧបករណ៍អេឡិចត្រូនិចផ្សេងទៀតដែលអាចប្រើក្នុងការលួចបន្លំ។
- ការប្រឡងតេស្តនឹងចាត់ទុកជាមោឃៈ ហើយបេក្ខជននឹងមិនអនុញ្ញាតឲ្យដាក់ពាក្យសុំប្រឡងតេស្តក្នុងរយៈពេល ០២ឆ្នាំ ក្នុងករណីដែលមានការលួចបន្លំក្នុងពេលប្រឡង។

- ប្រសិនបើព័ត៌មានផ្ទាល់ខ្លួន (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ) របស់បេក្ខជននៅលើលិខិតឆ្លងដែនមិនដូចព័ត៌មាននៅលើពាក្យសុំប្រឡងទេនោះបេក្ខជននឹងមិនត្រូវបានចុះឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកស្វែងរកការងារធ្វើក្រោមប្រព័ន្ធ EPS ក៏ដូចជាការបញ្ជូនទៅសាធារណរដ្ឋកូរ៉េឡើយ។ បេក្ខជនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបញ្ហាដែលបណ្តាលមកពីភាពខុសគ្នានៃព័ត៌មានទាំងនោះ។
- ដើម្បីបង្កើនប្រសិទ្ធភាពនៃការជ្រើសរើសពលករដែលមានចំណេះដឹងភាសាកូរ៉េឱ្យទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ អង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េនឹងធ្វើការផ្លាស់ប្តូរសំណួរនៃការប្រឡងតេស្តភាសាកូរ៉េ(EPS-TOPIK) ពីការដកស្រង់សំណួរពីសៀវភៅកម្រងសំណួរ-ចម្លើយ ជំនួសដោយការដកស្រង់ចេញពី "សៀវភៅស្តង់ដាសម្រាប់ការប្រឡងតេស្តភាសាកូរ៉េEPS-TOPIK (The Standard Textbook for EPS-TOPIK)" ដែលមានតែមេរៀនសុទ្ធ។ លោកអ្នកអាចទាញយក "សៀវភៅស្តង់ដាសម្រាប់ការប្រឡងតេស្តភាសាកូរ៉េ EPS-TOPIK " ជាសៀវភៅមេរៀន(PDF File) និងមេរៀនជាសំលេង(MP3) បានតាមរយៈគេហទំព័រដូចខាងក្រោម៖
  - គេហទំព័រ HRD-KOREA http://www.hrdkorea.or.kr/3/3/3/1/2
  - គេហទំព័រ EPS-TOPIK http://epstopik.hrdkorea.or.kr

  ※ លោកអ្នកអាចសាកល្បងអនុវត្តន៍ឆ្លើយសំណួរEPS-TOPIKបានដោយចូលទៅកាន់គេហទំព័រ៖ epstopik.hrdkorea.or.kr→ English homepage → Experience

- ការប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េមិនមានន័យថាបានប្រឡងជាប់ទៅធ្វើការនៅសាធារណរដ្ឋកូរ៉េឡើយ។
- បេក្ខជនដែលធ្លាក់តេស្តសុខភាព ឬធ្លាប់ស្នាក់នៅដោយខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ នឹងមិនត្រូវបានអនុញ្ញាតឲ្យដាក់ពាក្យសុំទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េឡើយបើទោះបីជាបានប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េក៏ដោយ។
- យោងអនុស្សរណៈយោគយល់ស្តីពីការបញ្ជូនពលករក្រោមប្រព័ន្ធ EPS មានតែគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសប៉ុណ្ណោះដែលមានសិទ្ធិបញ្ជូនពលករកម្ពុជាទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េ។ មានតែបេក្ខជនដែលបានប្រឡងជាប់នូវតេស្តសមត្ថភាពភាសាកូរ៉េ EPS-TOPIK និងបានចុះឈ្មោះចូលក្នុងបញ្ជីស្វែងរកការងារធ្វើប៉ុណ្ណោះដែលអាចត្រូវបានជ្រើសរើសដោយនិយោជកកូរ៉េតាមរយៈប្រព័ន្ធកុំព្យូទ័រ។ ភ្នាក់ងារឯកជនណាមួយដែលជាប់ពាក់ព័ន្ធនៅក្នុងដំណើរការបញ្ជូនពលករនឹងត្រូវធ្វើការផាកពិន័យតាមច្បាប់ជាធរមាន។
- ការប្រឡងតេស្តភាសាកូរ៉េនេះរៀបចំដោយ ក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ និងអនុវត្តដោយអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ ដោយមានការសហការជាមួយគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសដែលមានទីតាំងស្ថិតនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ ០២៣-៦៥២៥ ៧៧៧/ ០២៣-៦៤២៥ ៧៧៧/ ០១២-៤៦៦ ២២២/ នៅរៀងរាល់ម៉ោងធ្វើការ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ខែ មេសា ឆ្នាំ២០១៤

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការ

បណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេស

ពេជ សោភ័ន

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គ្រប់ស្ថាប័ន និងក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីចូលរួមផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ